THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
Superintendent

ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

សូជូនចំពោះ មាតាបិតា ក្រុមគ្រួសារ និងសិស្សានុសិស្ស របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ខ្ញុំសង្ឃឹមថាលោកអ្នកកំពុងមានការរីករាយ និងបាត់ការតឹងតែងចិត្ត នារដូវក្តៅនេះ។ ខ្ញុំសរសេរលិខិតដើម្បីជូនដំណឹងដល់លោកអ្នកថា យើងមានការខិតខំធ្វើការរៀបចំដើម្បីស្វាគមន៍សិស្សានុសិស្សរបស់យើងត្រឡប់មករៀននៅសាលាដោយផ្ទាល់វិញ ចំនួន ៥ ថ្ងៃ ក្នុងមួយសប្តាហ៍ ចាប់ផ្តើមនៅថ្ងៃអង្គារ ទី៣១ ខែសីហា ឆ្នាំ២០២១ -- *ដែលជាថ្ងៃចូលរៀនដំបូង*។

សុខភាព និងសុខុមាលភាព របស់សិស្សានុសិស្ស និងបុគ្គលិករបស់យើង នៅតែជាកិច្ចសំខាន់ជាងគេបំផុតរបស់យើង។ ដូច្នេះហើយ ពេញមួយរដូវក្តៅនេះយើង៖

- **តម្លើង ម៉ាស៊ីនបូមសំអាតខ្យល់ និងសម្អាតផ្ទៃ ឱ្យមានអនាម័យ** (air and surface purifier) ***គ្រប់***ទី**កន្លែងបង្ហាត់បង្រៀន និង *គ្រប់*សាលាទាំងអស់**
  ម៉ាស៊ីនបូមសំអាតឱ្យមានអនាម័យដ៏ទំនើបទាំងនេះគឺផ្អែកលើបច្ចេកវិទ្យាដែលបានបង្កើតឡើងដោយក្រុម ណាសា (NASA) ហើយបានបង្ហាញថាអាចកាត់បន្ថយវត្ថុធាតុចម្លងរោគបានយ៉ាងច្រើន ទាំងនៅក្នុងខ្យល់ និងលើផ្ទៃផ្សេងៗ។

- **លាងសម្អាត និងប្រើវត្ថុធាតុសម្លាប់មេរោគ នៅគ្រប់សាលាទាំងអស់**
  នេះរួមបញ្ចូលទាំងជញ្ជាំង កម្រាល គ្រឿងសង្ហារឹម ទ្វារ បង្អួច បន្ទប់ទឹក របងការពារ និងអ្វីៗជាច្រើនទៀត។ នៅពេលសាលាចាប់ផ្តើម ក្រុមអ្នកធ្វើការនឹងសម្អាតក្នុងកំឡុងថ្ងៃសិក្សា និងជាច្រើនម៉ោងក្រោយពេលចប់ថ្ងៃសិក្សា។

- **ធ្វើតេស្ត ម៉ាស៊ីនផឹកទឹកដែលមិនបាច់យកដៃប៉ះ** (touchless hydration stations) **ដែលនៅក្នុងសាលារបស់យើង ដល់ទៅជាង ១.០០០**
  យើងចង់ធ្វើឱ្យប្រាកដថាម៉ាស៊ីនទាំងនេះដំណើរការ ហើយអនុវត្តតាមបទប្បញ្ញត្តិទាំងអស់សម្រាប់ទឹកផឹកដែលមានសុវត្ថិភាព។

- **ថែរទាំ ម៉ាស៊ីនដាក់វត្ថុធាតុលាងដៃឱ្យមានអនាម័យដែលមិនបាច់យកដៃប៉ះ** (touchless hand sanitizer stations)

យើងនឹងបំពេញរាល់ម៉ាស៊ីនដាក់វត្ថុធាតុលាងដៃឱ្យមានអនាម័យនៅគ្រប់សាលាទាំងអស់ ហើយធានាថាសាលាទាំងអស់មានសំភារៈដែលពួកគេត្រូវការដើម្បីគាំទ្រការលាងដៃញឹកញាប់ដោយសិស្ស និងបុគ្គលិក។

- **បន្ថយកជាតិ អាសបែស្តូស** (asbestos) **ចេញពីសាលារបស់យើង**
  យើងបានយកសម្ភារៈដែលមានសារធាតុ asbestos លើសពី ២០ ម៉ាយ ចេញពីសាលារបស់យើង តាំងពីរដូវក្តៅមុន។ ឥឡូវនេះ យើងកំពុងយកសម្ភារៈទាំងនេះថែមទៀតចេញពីសាលា ចំនួន ៣៥ ដែលគម្រោងបរិស្ថាន និងគម្រោងកែលម្អ កំពុងតែដំណើរការ។

- **វិនិយោគជាង ១៦០ លាន ដុល្លារ ដើម្បីការស្ថាបនា ការសង់ឡើងវិញ និងការជួសជុលធំៗ របស់សាលា**
  នេះរួមបញ្ចូលទាំង ការប្រកដំបូលថ្មី ការបន្តប្រព័ន្ធអគ្គិសនីថ្មីៗ កែសំអាតថ្នាក់រៀន ប្តូរប្រព័ន្ធកំដៅ និងប្រព័ន្ធខ្យល់ចេញចូល សង់អាគារសិក្សាថ្មីពីរឱ្យរួចរាល់ និងអ្វីៗជាច្រើនទៀត។

សំណួរធំដែលគ្រប់គ្នាកំពុងសួរគឺ៖ តើវិធានការសុខភាព និងសុវត្ថិភាពអ្វីខ្លះនឹងត្រូវតម្រូវឱ្យមាននៅពេលសាលាបើកឡើងវិញ? នៅថ្ងៃទី៩ ខែកក្កដា មជ្ឈមណ្ឌលត្រួតពិនិត្យ និងការពារជម្ងឺ (CDC) បានចេញការណែនាំថ្មី។ ការណែនាំសម្រាប់ការការពារជម្ងឺ ខូវីដ-១៩ ក្នុងសាលា ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី១២ ដែលផ្តល់អាទិភាពដល់ការវិលត្រឡប់ទៅរៀននៅសាលាដោយផ្ទាល់វិញប្រកបដោយសុវត្ថិភាពដល់សិស្សានុសិស្សទាំងអស់ ជាមួយនឹងស្រ ទាប់សុវត្ថិភាពជាច្រើនដែលមាន។ ក្រសួងអប់រំរដ្ឋផិនស៊ីលវេនញ៉ា និងក្រសួងសាធារណៈសុខាភិបាលរដ្ឋផិន ស៊ីលវេនញ៉ា កំពុងពិនិត្យឡើងវិញនូវការណែនាំរបស់ CDC រួមជាមួយស្ថានភាពនៃ ខូវីដ-១៩ ក្នុងតំបន់។ ពួកគេមិនទាន់បានចេញសេចក្តីណែនាំស្តីពីសុវត្ថិភាពថ្មីសម្រាប់សាលានៅទីក្រុងហ្វីឡាដែលហ្វ្យ៉ានៅឡើយទេ ប៉ុន្តែពួកគេបានប្តេជ្ញាថានឹងធ្វើក្នុងពេលឆាប់ៗ។ យើងនឹងជម្រាបលោកអ្នកនៅពេលពួកគេចេញសេចក្តីណែនាំថ្មី។

នៅមានកិច្ចការជាច្រើនទៀតកំពុងកើតឡើងនៅរដូវក្តៅនេះ ហើយយើងនឹងផ្តល់ព័ត៌មានឱ្យបានទៀងទាត់ ដើម្បីឱ្យលោកអ្នកអាចមានទំនុកចិត្ត និងរំភើបចិត្តចំពោះការវិលត្រឡប់របស់កូនលោកអ្នកទៅរៀនដោយផ្ទាល់វិញ ដូចយើងដែរ។ លោកអ្នកក៏អាចមើលគេហទំព័រ philasd.org/ringthebell សម្រាប់ព័ត៌មានថ្មីៗ។

ពេលនេះ សូមថែរក្សាខ្លួន ហើយរីករាយនឹងរដូវក្តៅ!



William R. Hite Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា